ការសម្ភាសន៍របស់អ៊ីសុិន យ៉ាន

ក៖ អ្នកសម្ភាសន៍ឈ្មោះ ឡយ អូលីសា ខ៖ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ សុិន យ៉ាន

ពត៌មានសង្ខេបរបស់អ៊ីសុិន យ៉ាន

អ៊ីសុិន យ៉ាន មានអាយុ៤៤ឆ្នាំ គាត់មានស្រុកកំណើតនៅអង្គរក្រៅ
ខេត្តសៀមរាប។ គាត់មានបងប្អូនចំនួន៤នាក់
ហើយគាត់ជាកូនពៅក្នុងគ្រួសារគាត់។
គាត់ជួបបញ្ហារច្រើនណាស់ក្នុងជីវិតរបស់គាត់ ដូចជាភ្លើងឆេះផ្ទះ ចោរលួចម៉ូតូ
ប្តីរបស់គាត់ឆ្កែឆ្ពួតខាំទៀត។ គាត់មានមុខរបរជាអ្នកធ្វើស្រែចំការ
គាត់បាត់បង់ឱពុកតាំងពីគាត់នៅតូច។

ក៖ ចាសអ៊ី ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ីដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្ត
របស់អ៊ីហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយ
ដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។
គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍អំពីប្រវិត្តប្រជាជនខ្មែរ
ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់អ៊ីៗអាចស្គា
ល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់អ៊ីហើយចឹងនៅពេលដែលខ្ញុំស
ម្ភាសន៍ចប់ខ្ញុំសូមដាក់ការសម្ភាសន៍ណឹងនៅលើវេបសាយរបស់សាលាដែលមាន
ឈ្មោះថា www.cambodiaoralhistory.byu.edu
ចឹងតើអ៊ីយល់ព្រមឲ្យខ្ញុំដាក់ការសម្ភាន៍របស់អ៊ី
ចូលទៅក្នុងវេបសាយរបស់សាលាដែរឬក៏អត់អ៊ី?
ខ៖ ដាក់ទៅមិនថាអី។
ក៖ ចាស ចឹងសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍អ៊ីនេះគឺ នៅថ្ងៃទី០១ ខែកក្កដា
ឆ្នាំ២០២០
ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅទល់មុខប្រាសាទបាយ័ន្តនៅក្នុងខេត្ត
សៀមរាប ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះថាឡយ អូលីសា ចឹងខ្ញុំចង់សួរថា
តើអ៊ីមានឈ្មោះអ្វីដែរអ៊ី?
ខ៖ ខ្ញុំឈ្មោះ សុិន យ៉ាន។
ក៖ ចាស ចឹងអ៊ីមានឈ្មោះហៅក្រៅទេអ៊ី?
ខ៖ ទេ គេហៅមីនាងអីខ្លះដែរ តែប៉ុណ្ណោះឯង។
ក៖ ចាស ចុះអ៊ីមានអាយុប៉ុន្មានហើយឆ្នាំនេះអ៊ី?
ខ៖ ៤៤ឆ្នាំហើយ។
ក៖ អ៊ីនៅក្មេងដែរចឹង?
ខ៖ ចាស មានចាស់អី។
ក៖ ចាសចឹងចាំបាន តើអ៊ីកើតនៅថ្ងៃណាខែណាឆ្នាំណាដែរ?
ខ៖ អត់ដឹងផងវាភ្លេចអស់ចេះ។
ក៖ អ៊ីអាចប៉ាន់ស្មានឆ្នាំបានទេ?
ខ៖ ឆ្នាំម្សាញ់ វាអត់ដឹងខែដែរ ចាសដឹងតែឆ្នាម្សាញ់។
ក៖ ចឹងតើអ៊ីមានស្រុកកំណើតនៅណាដែរអ៊ី?
ខ៖ ខ្ញុំនៅអង្គរក្រៅនេះឯង កើតមកក៏យើញអង្គរក្រៅនៅនេះ។
ក៖ តើអ៊ីមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ?
ខ៖ បងប្អូន៤នាក់ទាំងខ្ញុំ។
ក៖ អ៊ីជាកូនទីប៉ុន្មានដែរ?
ខ៖ កូនទី៤ខ្ញុំពៅគេ។
ក៖ អ៊ីអាចរៀបរាប់ឈ្មោះបងប្អូនអ៊ីទាំងអស់បានអត់ ពីទី១ទៅណាអ៊ី?

ខ៖ ទីមួយឈ្មោះសុិន សំ ស្រី ទី២ឈ្មោះសិ◌ុន ស៊ីម ទី៣សុិន ដិ ស្រី។
ក៖ តើអ៊ុំបានចងចាំសាច់រឿងអ្វីខ្លះជាមួយប្អូនបងរបស់អ៊ុំតាំងពីក្មេងរហូតដល់ឥឡូវណឹង តើអ៊ុំធ្លាប់មានអនុស្សាវរីយ៍សប្បាយ ឬកំសត់ជាមួយគ្នាចឹងណាអ៊ុំ
កាលអ៊ុំនៅក្មេងៗណា? អ៊ុំធ្វើអ្វីខ្លះជាមួយបងប្អូនអ៊ុំនៅពីក្មេង?
ខ៖ ធ្លាប់ធ្វើស្រែចំការនោះជុំគ្នា បើក្រៅពីនោះមានធ្វើអីបើធ្វើការបែកគ្នា
គេធ្វើការនេះ
ខ្ញុំក៏ធ្វើការឯនោះ បើក្រៅពីធ្វើស្រែចំការ បើធ្វើការស្រែចំការធ្វើជុំគ្នា។
ក៖ ភាគច្រើនអ៊ុំនៅផ្ទះចឹងអ៊ុំលេងអីជាមួយគ្នាដែរ
ដែលធ្លាប់លេងល្បែងអីជាមួយគ្នា
អត់?
ខ៖ ចេះតែលេងបាយឡកបាយឡអី បើល្បែងរម៉ាល់អីដូចយាយគាត់ថា
ឈីងឈួងអី
អត់ចេះលេងទេ ចេះលេងតែបាយឡកបាយឡ
សូម្បីតែសព្វថ្ងៃតែអង្គុយរកនេះរកនោះ
ចុះវាធ្លាប់លេង
ធ្លាប់តែអ្នកផ្សេងក៏ដោយទៅអង្គុយខ្ញុំលេងបាយឡកបាយឡក្រៅពី
ណឹងក៏អត់ចេះលេង ហ្ការ៉ាក៏អត់ចេះ
ស្ពឹក៏អត់ចេះលេងដែរចេះតែបាយឡកបាយឡ
ចេះលេងតែចុះឯង។
ក៖ តើអ៊ុំធ្លាប់បានលេងល្បែងកំសាន្តអ្វីខ្លះជាមួយបងប្អូនរបស់អ៊ុំនៅពីក្មេងណា? ដូច
លេងល្បែងប្រជាប្រិយអីចឹងណា អ៊ុំធ្លាប់លេងអីជាមួយពួកគាត់អត់?
ខ៖ អត់ អត់ចេះលេងទាំងអស់ អត់ដែលប្រលែងគ្នាសោះ។
ក៖ ចឹងសព្វថ្ងៃនេះ តើបងប្អូនរបស់អ៊ុំណឹងគាត់រស់នៅឯណាដែរអ៊ុំ?
ខ៖ នៅស្រុកជុំវិញ នៅអង្គរក្រៅទាំងអស់គ្នាណឹងឯង តែនៅស្រុកឆ្ងាយៗពីគ្នា
មួយនោះខូចបាត់ទៅហើយ ខូចឆ្នាំទៅមិញខែធ្នូត បងគេនោះណា សុិន សំ ស្រី។
ក៖ គាត់ខូចយូរហើយតើហ៊ីអ៊ុំ?
ខ៖ ខូចឆ្នាំទៅមិញខែធ្នូត ខូចបាន១ឆ្នាំ ដល់ខែចែត្រនេះម៉ាក់ខ្ញុំគាត់ខូចដែរ។
ក៖ ចាសចូលរួមសោកស្តាយផងអ៊ុំ
ចឹងអ៊ុំដឹងថាពួកគាត់ប្រកបមុខរបរអីបងប្អូនដែលរស់
ទាំងប៉ុន្មាន បងប្រុសទី២ និង បងស្រីទី៣?
ខ៖ បងប្រុសនោះអត់មានធ្វើអីទេវាងដូចអស់ស្រួល ដូចខូចខួរក្បាលផឹកទៅ
ឈប់ផឹក
ហើយឲ្យទៅសុំសីល តែសុំមិនចូលវាដែរណា ដូចវិកលចរិត។
ក៖ ណឹងបងប្រុសទី២របស់អ៊ុំចឹង ចុះដល់បងស្រីទី៣?
ខ៖ បងស្រីក៏វាឈឺដែរ ឈឺឡើងស្គមដែរសល់តែស្បែកនិងឆ្អឹងដែរសព្វថ្ងៃនេះ
នៅមើល
តែចៅវាស្គមឡើងតូចញ៉ីបជាតែខ្ញុំទេ ពួកគេវាឈឺ។
ក៖ ចឹងទាក់ទងជាមួយនិងម្តាយអ៊ុំម្ត
ខ៖ ឈ្មោះយាយខន ប៊ុនខន ឪគាត់ឈ្មោះតាប៊ុន
ក៖ អ៊ុំចាំថ្ងៃខែឆ្នាំកំណើតរបស់ម្តាយអ៊ុំទេ?
ខ៖ អត់ចាំណា។
ក៖ តែអ៊ុំអាចប៉ាន់ជាឆ្នាំបានទេ?
ខ៖ មិនដឹងឆ្នាំណាព្រោះគាត់ខូចអាយុ៩២ឆ្នាំហើយ គាត់ឆ្នាំមមែ។
ក៖ ចឹងអ៊ុំដឹងថាគាត់មានទីកន្លែងកំណើតនៅឯណាទេអ៊ុំ?
ខ៖ ម៉ាក់ខ្ញុំនៅឯកំពង់ចាម ស្រុកកំណើតគាត់ណា
ដល់គាត់ដូចថាកាលនោះគាត់ស្អាត

គាត់អ្នកលេងល្ខោន ចាសសិល្ប:ល្ខោនអីទៅក៏គេយកមករាំច្រៀងនៅព្រះអង្ក
គោកធ្លកនេះឯង លឺប្រវិត្តគាត់និយាយប្រាប់ខ្ញុំ
ដល់ពុកខ្ញុំក៏យើញគាត់ទៅក៏ស្រលាញ់
ទៅពីដើមមិញគេផ្សំផ្ត◌ុ◌ំ◌ឲ្យ។
ក៖ ចុះម្តាយរបស់អ៊ីគាត់ជាមនុស្សប្រភេទម៉េចដែរអ៊ី?
បើនិយាយពីអត្តចរិករបស់គាត់?
ខ៖ ចូលចិត្តសប្បាយ។
ក៖ កាច ឬ ស្លូត?
ខ៖ កាច កាច តែចូលចិត្តសប្បាយ គាត់ចូលចិត្តដើរសប្បាយប៉ាដោយ
បើគាត់រកបាន
ដើរលេងសប្បាយប៉ាដោយណា សប្បាយបានអាយុវែង
បើកើតទុកដូចខ្ញុំមិនបានអាយុ
វែងទេណា គាត់ទៅគប់ប៉េងប៉ោងអីទៅ
មិនដែលនិយាយកុហកអីគាត់សប្បាយមែន
ណា គាត់ប្រាក់តិចក៏ដើរសប្បាយទៅផ្លូវ៦០ ទៅភ្នំពេញអី
និយាយទៅសប្បាយរហូត
គាត់អត់គិតថា ស្មាទោសគាត់ងាប់ទៅមិនដឹងកូនបានប្រាក់អីធ្វើបុណ្ឃ
គាត់អត់គិត
ទេអាណឹងនោះ អញងាប់ទៅថា ពេលម៉ែឯងបានលុយសប្បាយមាំម្លេះ
គាត់ថាងាប់
ទៅយកអញទៅដុតទៅគាត់គិតចុះឯងណា
ពីណាមិនគិតអញក៏អត់ទៅយកអញទៅ
ចោលក្នុងដុបទៅ គាត់អាយវែងគាត់សប្បាយ បើហូបគាត់ហូបឡើងទាល់ថា
គាត់
អត់បាយតែ២ពេលទេ បានគាត់ដាច់ខ្យល់ងាប់។
ក៖
ចាសចុះអ៊ីចងចាំសាច់រឿងអ្វីខ្លះជាមួយម្តាយរបស់អ៊ីតាំងពីក្មេងរហូតដល់គាត់ផុ
ត
ទៅ? អ៊ីមានអនុស្សាវរីយ៍អីខ្លះជាមួយគាត់ដែលអ៊ីមិនអាចបំភ្លេចបាន?
ខ៖ ថាគាត់កំសត់អីណឹង គាត់អត់ឃ្លានអីណឹង
គាត់អស់ឃ្លាននោះឯងគិតមើលពុកខ្ញុំ
ងាប់តាំងពីខ្ញុំកើតបាន៣ខែ ខ្ញុំកើតបាន៣ខែទៅក៏ពុកខ្ញុំងាប់ចោលទៅ
គាត់កំសត់គាត់
ដូចថាគាត់មានដីមានធ្លាតែគាត់អត់ចេះលក់ចិញ្ចឹមកូនទេ
គាត់តែដើរបានអីចេះតែយក
ទៅដូរស្រូវគេ គាត់ចេះស្ទូចត្រីដូរស្រូវ ដូរអង្ករប្រវិត្តគាត់និយាយប្រាប់ណា
បើអាត្រង់ថាឲ្យចេះលក់ដី
ឬមួយអារបស់ណាធូរៗស្រួលគាត់អត់ដែលលក់ដែលអីទេ
គាត់ទុកឲ្យកូនចរិកគាត់ល្អចឹងឯង
ដីអីមានច្រើនដែរគេសុំឲ្យទាំងហិកតាគាត់អត់លក់
ទេ គាត់សុទ្ធចិត្តឲ្យគេ គាត់អត់លក់ចាយទេ
គាត់សុទ្ធចិត្តដើររកសុំអង្ករសុំអីគេហូប
ទៅចុះណាយាយ គាត់ចិញ្ចឹមកូន គាត់ទូលាយណាស់
គាត់អាយុវែងបើគាត់អត់ដែល
គិតកើតទុក្ខផងម៉ាក់ណាចឹងបានគាត់អាយុវែងយ៉ាង។
ក៖ ចាសអ៊ីចាំទេកាលម្តាយអ៊ីនៅរស់ គាត់ធ្វើការងារអ្វីដើម្បីចិញ្ចឹមជីវិតនិងក្រុម
គ្រួសារដែរ?

ខ៖ គាត់ដើររកតិតក់ដើររកដូចថាដូរស្រូវដូរអង្ករគេហូប ដូចមានរបស់យកទៅដូរ
ទិញច្រឡះទិញអីគេ គាត់អីផ្សេងបានជាលុយខ្លះទៅទិញរបស់េគក៏យកទៅដូរ
ជាអង្ករ ជាស្រូវយកមកហូប បើនៅជំនាន់ខ្ញុំនៅតូចៗវិញ ២នាក់យាយនោះឯង
គាត់ដើរនាទៅដូរទៅសុំអង្ករសុំខោអាវគេស្លៀកនៅឯផ្សារក្រោមអីនោះ ដើរសុំ
ណាកាលខ្ញុំតូចៗណា ខ្ញុំតាមគាត់ ដើរណាជិតឡើង ដូចសព្វថ្ងៃដែលដើរ
ដើរសុំគេស្លៀកពាក់ យកមកឲ្យកូនស្លៀកពាក់តាំងពីខ្ញុំនៅតូចៗ ពេលខ្ញុំធំមក
ដឹងតែគាត់ពិបាកចុះណា មិនដែលអៀនគេទេដឹងតែដើរសុំគេស្លៀកពាក់
ដើម្បីកូន ខ្ញុំដឹងថាប្រវត្តិគាត់កំសត់ចុះដល់ពេលគាត់ឈឺប៉ុន្មានឆ្នាំនេះ
ខ្ញុំមើលគាត់
ថែគាត់តែរហូតមិនដែលមានបងប្អូនណាទៅជួយមើលទេ
បងប្អូនមានមែនប៉ុនអត់មាន
ទៅជិតណា ពេលថាឲ្យថាម៉ាក់នឹក ខំទៅប្រាប់បងអើយទៅលេងម៉ាក់ម្តង
ម៉ាក់គាត់នឹក
មិនដែលមានបងប្អូនណាទៅ
ស្អប់អាទាល់តែគាត់អស់បុណ្យនោះគាត់នេះទៅបានទៅ
យំបោកខ្លួន ខឹងមែន ប្រវិត្តគាត់កំសត់មែន។
ក៖ តើម្តាយរបស់អ៊ុធ្លាប់ប្រាប់សាច់រឿងរបស់គាត់កាលពីគាត់នៅក្មេងៗដល់
អ៊ុស្តាប់ទេ? ដូចថាគាត់នៅពីក្មេង រៀបរាប់រឿងគាត់កាលពីក្មេងម៉េចៗចឹងណា
គាត់ធ្លាប់និយាយប្រាប់អ៊ុទេ?
ខ៖ គាត់ប្រាប់ថាពេលគាត់កើតបានពីម៉ែគាត់បានអាយុ៧ឆ្នាំ
គាត់មកនៅជាមួយម្តាយ
មីងនៅភ្នំពេញ ដល់មកនៅទៅរហូតដល់គាត់ធំទៅគាត់រៀនទៅ គេរើស គេលេង
ល្មោនរបាំអីនៅចុះដែលខ្ញុំប្រាប់ចុះទៅ ដឹងតែប្រវិត្តគាត់ប៉ុណ្ណោះឯង
បើត្រង់ថាម៉ែឲ្យ
គាត់នៅរស់គាត់ត្រលប់ទៅរកវិញយើញអី ដល់ទៅនាំខ្ញុំទៅខ្ញុំធំហើយ
ទៅកន្លែងដីគេ
ដែលគាត់ធ្លាប់រស់នៅ គេធ្វើអូតែលធំៗ ធ្វើរូបសុទ្ធតែប្រឹសមាសប្រឹសអីទៅណា
ពេញ
បឹមនោះទៅគាត់ក៏យំស្តាយថាដីគាត់ធ្លាប់រស់នៅគាត់ទៅរកម្តាយមីងគាត់
ទៅក៏ទៅរក
ឯណាយើញ ទៅសួរគេទៅគេថាដីនេះខ្ញុំបានទិញហើយថា
គាត់ក៏នាំខ្ញុំត្រលប់មកវិញ
អត់បានជួប ក៏គាត់នៅតែេនេះទៅណា មិនដែលបានទៅរកអីនរណាយើញណា
ប៉ុណ្ណោះឯងប្រវិត្តគាត់។
ក៖ ឥឡូវយើងបាននិយាយគាត់ពីប្រវិត្តរបស់ម្តាយអ៊ុច្រើន
ល្ងវទាក់ទងនឹងប្រវិត្តរបស់
ឪពុកអ៊ុម្តង តើឪពុករបស់អ៊ុគាត់មានឈ្មោះអ្វីីដែរអ៊ុ?
ខ៖ ឈ្មោះតាសុិន តែខ្ញុំអត់ស្គាល់ត្រកូលអីគាត់ទេ អត់ដឹងទាំងអស់ណា
ខ្ញុំកើតអត់ទាន់
ទៅ
ខ្ញុំកើតបានអាយុពាខែបានអីស្គាល់សូម្បីតែរូបថតមិនដែលថតរូបឲ្យកូនមើលផ
ង។
ក៖ ចឹងអ៊ុប្រហែលជាមិនចាំថ្ងៃខែឆ្នាំកំណើតរបស់ឪពុកអ៊ុទេ?
ខ៖ អត់ អត់ដឹងទាំងអស់។
ក៖ ចុះអ៊ុដឹងទេថាពេលគាត់ខូចអាយុប៉ុន្មាន?
ខ៖ អត់ដឹងដែរ។
ក៖ គាត់ចាស់ដែរហើយអ៊ុហីពេលគាត់ខូច?

ខ៖ មិនដឹងចំណាស់ប៉ុន្មានយាយ យាយឯងដែរដឹងអាយុប្រហែលចំណាស់ប៉ុណ្ណា បើមិនស្គាល់ដែរណា?
ក៖ ចុះអ៊ីដឹងថាគាត់មានកន្លែងកំណើតនៅឯណាដែរអ៊ី?
ឱពុករបស់អ៊ីគាត់កើតនៅ
ខេត្តណាដែរ?
ខ៖ អត់ដឹងដែរណា។
ក៖ គាត់មិនមែនអ្នកនៅសៀមរាបទេ?
ខ៖ អត់ទេ គាមគិតទៅមិនមែនអ្នកសៀមរាបទេ មិនដឹងនៅឯណាដែរ។
ក៖ តើអ៊ីផ្លាប់លឺម្តាយរបស់អ៊ីនិយាយថាជ៉ារបស់អ៊ីមនុស្សប្រភេទម៉េចអីម៉េចអត់?
ខ៖ ដឹងតែថាប៉ុនរក្សាកូនស្រលាញ់កូនដឹងតែប៉ុណ្ណោះបើថា ត្រង់ចរិតគាត់ម៉េចអីថាអត់ចេះផឹកអត់ចេះអី លឺម៉ាក់គាត់និយាយចុះ
ថាស្លូតមនុស្សនោះដឹងតែម៉ាក់ប្រាប់
ប៉ុណ្ណោះ បើរឿងអីចរិតគាត់ម៉េចអត់ដឹងដែរនាង។
ក៖ តើអ៊ីផ្លាប់បានរៀនបទពិសោធន៍អ្វីខ្លះ បទពិសោធន៍ជីវិតអ្វីខ្លះពីឱពុកម្តាយរបស់អ៊ីដែរ? ម្តាយរបស់អ៊ីបានបង្រៀនអ្វីខ្លះមកាន់អ៊ី?
ខ៖ បង្រៀនអារឿងរកស៊ីរកអីណឹងនាង ប្រាប់ថាកុំឲ្យចេះលួចគេឲ្យតែកាន់ចិត្តថែចិត្ត
ត្រង់ទៅ ប៉ុណ្ណោះក៏សង្គមគេចូលចិត្តហើយគាត់ថាឲ្យតែខំរកស៊ីទៅ ហើយសម្លៀកបំពាក់ឲ្យចេះមើលចុះគាត់ប្រាប់តាំងពីខ្ញុំនៅតូច ឲ្យតែកូនខំ។
ក៖ ចាសអ៊ី តើយាយខាងម្តាយរបស់អ៊ីគាត់មានឈ្មោះអ្វីដែរ?
ខ៖ ខ្ញុំអត់ស្គាល់ដែរ ម៉ាក់អត់ដែលនេះប្រាប់ផងម៉ាក់អត់ដែលនិយាយសួរនាំមិនដែល
បានសួរ ខ្ញុំស្គាល់តិចៗដែរមិនមែនដឹងទាំងអស់ គាត់យាយខៀវ
ឈ្មោះម៉ែយាយខន
ឈ្មោះយាយខៀវ យាយឈ្មោះគាត់យាយខៀវ។
ក៖ អ៊ីតើយាយខាងម្តាយរបស់អ៊ីគាត់នៅខេត្តណាវិញ? គាត់អ្នកខេត្តណាស្រុកកំណើតគាត់?
ខ៖ នៅឯកំពង់ចាមនោះ។
ក៖ តើម្តាយរបស់អ៊ីគាត់ដែលនិយាយរឿងយាយរបស់អ៊ីឲ្យអ៊ីស្តាប់ទេ។
ខ៖ អត់ អត់ដែលនិយាយសោះយាយណា ម៉ាក់គាត់អត់ដែលនិយាយសោះរឿងម៉ែគាត់។
ក៖ ចុះខាតាវិញអ៊ី ម្តាយរបស់អ៊ីគាត់ដែលនិយាយប្រាប់អ៊ីអីអត់?
ខ៖ អត់ អត់ដែលនិយាយណា។
ក៖ ចុះអ៊ី
តើឱពុកម្តាយរបស់អ៊ីផ្លាប់និយាយរឿងជីដូនជីតារបស់អ៊ីទាំងខាងឱពុកទាំងខាងម្តាយឲ្យអ៊ីស្តាប់ទេ?
ខ៖ អត់និយាយ មិនដែលបាននិយាយទេនាង មានតែគាត់សប្បាយគាត់ទៅដើរគាត់
មិនដែលបាននិយាយអី អត់ដែលដឹងកូននេះផង ហើយគាត់ដើរតែសប្បាយគាត់ពេល
ខ្ញុំធំមកគាត់មិនដែលកំបុិកកំប៉ុកកូនផងគាត់ដើរសប្បាយ
គាត់ដើរលេងសប្បាយចាយ
តែគាត់។
ក៖ អ៊ីចុះ តើយាយខាងឱពុករបស់អ៊ីមានឈ្មោះអីដែរ? អ៊ីដឹងអត់ខាងឱពុក?
ខ៖ អត់ស្គាល់ ងងឹតសូន្យមិនដឹងជាទៅនៅឯណាអីណី
ខ្ញុំមិនដឹងគាត់កើតនៅឯណា

ស្រុកគាត់នៅឯណា កើតអត់ទាន់មិនដឹងមុខមាត់ម៉េច
សូម្បីតែសុបិន្តក៏មិនដែលសុបិន្ត
ឃើញ។
ក៖ អ៊ីចឹងខ្ញុំសួរអ៊ុតិច តើអ៊ីរស់នៅក្នុងខេត្តសៀមរាបនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ?
ខ៖ តាំងពីកំណើតមក អាយុខ្ញុំ៤៤ហើយនៅតែនេះរហូតឯងណា
ក៖ តើអ៊ីមានសាច់ញាតិដែលរស់នៅក្រៅប្រទេសទេអ៊ុ ដូចនៅអាមេរិក
អូស្ត្រាលី កាណាដាអ៊ីអត់?
ខ៖ អត់មានទេនាង មិនដែលមាន។
ក៖ ចាសអ៊ូ តើស្វាមីលោកអ៊ីគាត់មានឈ្មោះអ្វីដែរអ៊ុ?
ខ៖ ឈ្មោះម៉ែន ម៉ន ម៉ែន ឪ!ឈ្មោះម៉ន។
ក៖ តើអ៊ីបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីអ៊ីឆ្នាំណាដែរ?
ខ៖ ភ្លេចទៅហើយ ចាស់ហើយមិនចាំ។
ក៖ បើអ៊ីអត់ចាំទេ ពេលអ៊ីការអ៊ីអាយុប្រហែលប៉ុន្មាន?
ខ៖ ខ្ញុំអាយុ១៨ឆ្នាំ។
ក៖ តើអ៊ីបានចាកន្លែងដែលអ៊ីបានរៀបអាពាហ៍ពិពាហ៍ទេ?
ខ៖ នៅផ្ទះ នៅអង្គរក្រៅនោះឯង។
ក៖ តើអាពាហ៍ពិពាហ៍ណឹងរៀបរបស់អ៊ីណឹងចំឡើងដោយឪពុកម្តាយ
ត្រូវទេអ៊ីអត់មានការបង្ខំចិត្តអីទេអ៊ុ?
ខ៖ ម៉ែឪរៀបឲ្យនាង បើដូចថាបានគ្នាមុនណា គេចាប់ខ្ញុំមុនទៅ។
ក៖ អ៊ីខ្ញុំសូមសួរតិចកាលអ៊ីរៀបការណឹងបានទទួលផ្លែដំនូនទេអ៊ី បានទទួលផ្លែដំនូនប៉ុន្មានដែរពីស្វាមីរបស់អ៊ី?
ខ៖ បានតើ កាលនោះគេឲ្យ៨ជី តែយូរហើយផ្លែ។
ក៖ អ៊ីអាចប្រាប់ពីពេលវេលាដំបូងដែលជួបស្វាមីរបស់អ៊ីបានទេ
អ៊ីជួបនៅឯណាហើយ
ហើយម៉េចបានអ៊ីផ្តើមមានសេចក្តីស្នេហាជាមួយគ្នា?
ខ៖ ផ្ទះជិតគ្នានោះ ម៉ែគេមកទិញដីម៉ាក់ខ្ញុំលក់ទៅ ម៉ែខ្ញុំអត់ចេះលក់ទៅឲ្យអ៊ីជីមលក់ឲ្យ
លក់គេយកប្រាប់ខ្លួនគេ គាត់ឲ្យទៅគេ អ៊ីជីមអ្នកលក់ណាម៉ែបងជួនណា ទៅម៉ាក់មិន
ដែលបានយកលុយអី តែគេយកចាយម៉ាក់ចិត្តល្អនោះ
ទៅក៏ទិញដីជាប់នៅជិតគ្នានោះ
ឯងណា។
ក៖ អ៊ីស្រលាញ់គ្នាប្រហែលប៉ុន្មានឆ្នាំដែរបានអ៊ីរៀបការ?
ខ៖ ៤ ១០ឆ្នាំហើយដឹង គេថាឃើញខ្ញុំតាំងពីតូច ខ្ញុំលេងតែបាយឡកបាយឡ អង្គុយតែ
ស្រាតឃើញទាំងអស់គេថា។
ក៖ ចឹងបានន័យថាប្តីរបស់អ៊ីគាត់អាយុរៀងច្រើនជាងអ៊ី?
ខ៖ បងខ្ញុំមួយឆ្នាំ នោះឯងគេថាឃើញខ្ញុំលេងបាយឡកបាយឡអង្គុយស្រាត។
ក៖ ចឹងហេតុអ្វីបានជាអ៊ីជ្រើសរើសរៀបការជាមួយស្វាមីរបស់អ៊ី?
ខ៖ ចុះបើគេស្រលាញ់ទៅ ស្រលាញ់គ្នាទៅវិញទៅមក ម៉ែឪបំបាក់ដែរតែអត់ អត់ឈ្នះ
កូនស្រលាញ់គ្នាក៏ នោះឯងទៅក៏
សូម្បីតែគេអត់ឲ្យអីក៏អត់ទៅចុះឲ្យយើងរស់ជាមួយ
គ្នា សូម្បីតែកង់ក៏គេយក ខែរួករខ្ញុំ២ជីគាត់យកអស់យាយខ្ញុំម៉ាក់ខ្ញុំនេះណា ទៅកង់ខ្ញុំ
ធ្វើការមួយក៏គេយកម៉ត់

ទៅគាត់ថាធ្វើម៉េចបើម៉ែក្មេកឲ្យកាម៉ែលមួយដាំបាយថា
ឲ្យការម៉ែលមួ្ួយដាំបាយសុខចិត្តទៅណា អត់ក៏អត់ទៅ។
ក៖ អ៊ុចឹងអ៊ុមានកូនប៉ុន្មានដែរអ៊ុ?
ខ៖ សព្វថ្ងៃនៅកូន៦នាក់ កូន៩នាក់តែងាប់អស់៣នាក់ទៅ នៅតែ៦ទេ
ក៖ អ៊ុអាចនិយាយបានទេ
កូនរបស់អ៊ុសុទ្ធតែអ្នករៀបការហើយអស់ហើយត្រូវទេអ៊ុ?
ខ៖ នៅទាំងអស់នេះបន្ទុកទាំងអស់នេះ ចិញ្ចឹមទាំង៦នាក់នេះ៦ង នៅរៀន។
ក៖ ចឹងបានន័យថានៅក្មេងៗដែរអ៊ុ? អាយុប្រហែលន្មានឆ្នាំដែរអ៊ុ?
ខ៖ បងគេឆ្នាំថោះ អាយុ២០លើស ២០ន្មាន ២២ ឬ ២១
ទៅបន្ទាប់មកទៀតឆ្នាំមមី ១៩ឆ្នាំហើយ
បើតាមវានិយាយថាទាល់តែអាយុតាមដែលវានិយាយ មីស្រីវាថាទាល់តែ
គេ៣០បានគេយក បើអាប្រុសគេថា២៧បានគេយក
ម៉េចក៏ម៉េចទៅតាមតែកូនម៉ែមិន
ដែលបានទៅឃាត់មិនឲ្យយក តាមតែកូនទៅកូនយកក៏យក
តែកូននៅរៀនទាំងអស់
បើកូនមិនទាន់ចេះស្រលាញ់នរណាផងទាំងអស់ណឹង មុខតែក្រម៉ូរ
បើមីស្រីមុខតែក្រម៉ូរមិនដែលចេះនិយាយជាមួយនរណា
មិនដែលចេះស្រលាញ់គេទេ
គេ២ងគេបានចៅឡើងគ្រប់គ្នា យីចង់បានស្រលាញ់ចៅកូនគេ កូនអាលីណា
គេទៅ
ប៉ោយប៉ែតឡើងមួយខែហើយណា ស្រឡាញ់ឡើងអារលាយនេះនឹកណា
យកទៅបាត់
កូនវាត្រូវជាក្មួយណា
ទៅក៏ចេះតែថាអាអើយឆាប់យកប្តីយកប្រពន្ធអញចង់បានចៅ ម៉ែ
ឯងចេះតែបង្ខំថាកូនមិនទាន់រៀនចប់ផង ខ្ញុំមិនទាន់រៀនចប់មិនយក
ចង់បានចៅ។
ក៖ អ៊ុកូនអ៊ុដែលខូចពីនាក់ណឹងគាត់កូនទីន្ទានដែរ?
ខ៖ បងគេ២នាក់ខូចទាំងពីរនាក់នោះ២ង ទៅក៏បន្ទាប់អាពៅគេនោះណា។
ក៖ កូនពៅគេណឹងខូចដែរ?
ខ៖ បន្ទាប់អាពៅនោះណា ខូចទៅដែរពីនាក់កុំអីបងគេនោះអាយុ២៤
២៥ឆ្នាំហើយ។
ក៖ គាត់កើតអីដែរអ៊ុ គាត់ឈឺឬក៏ម៉េចអ៊ុ?
ខ៖ ឈឺ។
ក៖ គាត់ឈឺទាំងពីនាក់?
ខ៖ ចាស ឈឺសម័យនោះទៅមានពេទ្យ២ណាល្អល្អិត
ពេទ្យកន្ទបុប្ផាមិនទាន់កើតផង
អូនកាលនោះ។
ក៖ តើអ៊ុចេះអាន និង ចេះសរសេរអក្សរខ្មែរទេ?
ខ៖ មិនដែលបានរៀនទេ អាល័យតែចង់ដើរតាមម៉ាក់ មិនដែលបានរៀនអី
ដល់កូនវា
ចេះ១រៀនឆ្លាតឡើងខ្ញុំអរឡើង តែខ្ញុំមិនដែលបានរៀនទេ
បើឪវាមិនដែលចេះអីបង មិន
ដែលចេះអីឪវាណឹងធ្វើការគេស្រលាញ់ណាស់ ដោយសារអត់ចេះ បើសិនជាចេះបាន
ធ្វើចៅហ្វាយនោះមែនណា ចាសអត់ចេះអក្សរ។
ក៖ ចុះអ៊ុ០ុ០ំបានទៅរៀនទេអ៊ុកាលពីក្មេងៗ?
ខ៖ ទៅរៀនតែអត់យកចិត្តទុកដាក់ណា អត់រៀនមែន អត់យកចិត្តទុកដាក់
លេងតែ

បាយឡកបាយឡ ត្រូវៃច្រើនពេកឈប់ទៅ
អត់ចេះមែនណឹងឯងខ្ញុំទៅកុហកធ្វើអីខ្ញុំ។
ក៖ ចុះកាលអ៊ុទៅរៀនណឹងរៀននៅសាលាណាវិញអ៊ុ?
ខ៖ ខ្ញុំរៀននៅសាលាអង្គរក្រៅនេះឯង អង្គរក្រៅក្នុងស្រុកខ្ញុំ
ក៖ តើអ៊ុចេះភាសាអ្វីផ្សេងទេក្រៅពីភាសាខ្មែរយើងទេ ដូចអង់គ្លេស?
ខ៖ អូដែលចេះទេ ចេះតែហៅបារាំង២ ៣ ម៉ាត់នេះណា ហេឡ មកលេងព្រះអង្គក៏
ហេឡ sir presh buda ប៉ុណ្ណោះឯង។
ក៖ ចុះអ៊ុ
កាលពីអ៊ុនៅពីក្មេងមានមិត្តភិក្តស្និតស្នាលដែលធំធាត់មកជាមួយគ្នាទេអ៊ុ?
ខ៖ មានតែមិត្តភិក្ត
ដូចថាធ្វើការតាមប្រាសាទបោសសំអាតជំរះតាមប្រាសាទទ្រួសព្រៃ
តាមដុបតាមអីនេះទៅក៏ស្គាល់គ្នាក៏មានចុះណា។
ក៖ ចុះអ៊ុស្គាល់ឈ្មោះពួកគាត់ទេអ៊ុ មិិត្តភិក្តជិតស្និតរបស់អ៊ុណឹង?
ខ៖ ឈ្មោះធឹ នៅឯដីថ្មី តែសព្វថ្ងៃគេបានប្តីទៅបាក់គ្នាទៅឆ្ងាយៗហើយ។
ក៖ អត់អីទេអ៊ុ ចុះអ៊ុមានអុស្សាវរីយ៍អីខ្លះជាមួយពួកគាត់
អនុស្សាវរីយ៍ដែលអ៊ុចងចាំ
ដល់សព្វថ្ងៃ តាំងពីអ៊ុនៅក្មេងៗជាមួយពួកគាត់?
ខ៖ ស្គាល់អនុស្សាវរីយ៍ដែលយើងដើរទ្រួសកាប់ដំបូក ជំរះតាមដុបតាមព្រៃនេះ
តាំងពី
ប្រាសាទនៅស្តុកមិញ ក៏ពួកខ្ញុំធ្វើការជំរះឡើងច្រើន មានអង្គ្រង ស្រម៉ោច ក្អែប
អូកាល
នោះក្អែបណាទើបតែជំរះដំបូងបងស៊ុន
ក្អែបពេញដុបពេញព្រៃកាលខ្ញុំនៅក្រមុំៗខ្ញុំធ្វើ។
ក៖ តើអ៊ុធ្លាប់ធ្វើស្រែចំការទេអ៊ុ?
ខ៖ ធ្វើ។
ក៖ តើមានផលលំបាកអ្វីខ្លះអ៊ុក្នុងការធ្វើស្រែចំការណឹង?

ខ៖ ពិបាកអត់ទឹក ចាំតែទឹកភ្លៀងទៅណា
ដល់អាទឹកភ្លៀងអត់ក៏ធ្វើអត់បានហូប ប៉ុន្តែ
ដល់នេះគេកាយប្រឡាយនាំគ្នាលៃប្រាក់អ្នកស្រុកគ្នាយើងមកទៅកាយប្រឡាយបា
ន
ចូលទឹក ធ្វើបាន២ឆ្នាំហើយ
ប៉ុន្តែទំនប់បាក់ទៀតទៅហើយលឺគេថាបាក់បាត់ទៅហើយ
មិនដែលបានហូបទេយាយ
សង្ឃឹមតែទឹកភ្លៀងនោះឯងបើទឹកភ្លៀងអត់មិនដែលបាន
ហូប បាក់ទំនប់អីដែលពូម៉េងកាយកាលណោះណា។
ក៖ ចុះអ៊ុធ្លាប់ប្រកបអាជីវកម្មជាលក្ខណៈគ្រួសារអីទេអ៊ុ ?
ដូចបើការកស៊ុអីចឹងណាអ៊ុ?
ខ៖ ពីដើមមិញខ្ញុំលក់។
ក៖ អ៊ុលក់អីគេអ៊ុ?
ខ៖ ខ្ញុំលក់ដូចជា ខ្ទឹម ម្សៅស៊ុប អំបិលអី លក់ឥវ៉ាន់ចាប់ហួយ
ក៖ អ៊ុធ្លាប់ចិញ្ចឹមជ្រូក ចិញ្ចឹមគោ ចិញ្ចឹមមាន់អីទេអ៊ុនៅផ្ទះ?
ខ៖ បើចិញ្ចឹមមាន់ ចិញ្ចឹមគោ ចិញ្ចឹមជ្រូកអត់បានដែរ
ចិញ្ចឹមដែរតែចិញ្ចឹមអត់សល់
បើចិញ្ចឹមគោ និង មាន់បាន
យាយអើយបងអើយមាន់ដែលគេយមកថ្វាយព្រះអង្គ
មួយនោះងាប់ហើយ ងាប់កាលម្សិលថ្ងៃនេះណា

ចាសអាសអាមាន់ផ្ទឹងខ្ទៅនោះដាប់
ជាត់ហើយ ឈឺដាប់ទាំងអស់មិនដែលមានសល់ មាន់ឡើង៥០ជាងណាដាប់សល់
តែមេ២ ខ្ទៅមួយ ពណ៌ប្រផេះមួយប៉ុណ្ណោះបងអើយដើរដល់ផ្ទារពោះ ដាប់ឡើងអស់
រលីងចេះឈឺ រ៉ាឈឺក្តៅលើកមុននេះណា។
ក៖
អ៊ីធ្លាប់ប្រកបមុខរបស់អ្វីខ្លះដើម្បីរកប្រាក់ចំណូលចិញ្ចឹមជីវិតរបស់អ៊ី?អ៊ីធ្វើអ្វីខ្លះ
ដើម្បីបានប្រាក់យកមកចិញ្ចឹមក្រុមគ្រួសារអ៊ី?
ខ៖ ពីដើមមិញធ្វើស្លឹក ស្លឹកដែលលក់ឲ្យភ្ជៀរ ដល់កាលខ្ញុំឈឺនេះទៅអត់បានធ្វើ
ដល់ជារ៉ាងចុះថត ថតតែគេឯងអត់បានថតខ្ញុំ ខ្ញុំក៏ដាច់ម្ហ៊ីយទៅ អត់ទៅ។
ក៖ កាលដែលអ៊ីធ្វើណឹងគេលើកយកទៅលក់ត ឬក៏ម៉េចអ៊ី?
ខ៖ គេលើកយកទៅលក់ត គេយកទៅលក់ទៀតទៅក៏ដូចយើងធ្វើមួយ
១២០០រៀល
គេឲ្យយើង១១០០រៀលទៅ គេយក១០០រៀល ចាសគេលើកពីយើង។
ក៖ ប៉ុនៗណាដែរអ៊ី ធ្ងៃៗទេ?
ខ៖ ស្លឹក ប៉ុនណេះទៅប្រវែងណេះ ៤ជ្រុង ត្រូបពងទា១០ត្រាប់
ធ្វើប៉ុនណេះឯងដាក់ពង
ទា២ត្រាប់ៗ ចូលបាន១០ត្រាប់ទៅលក់ឲ្យភ្ជៀរ។
ក៖ អាណឹងធ្វើស្លឹកឬស្សីមែនអ៊ី?
ខ៖ ធ្វើស្លឹកត្នោត។
ក៖ ចាសចុះអ៊ីធ្លាប់ធ្វើអីផ្សេងទៀតអត់ ឬក៏ធ្វើតែអាណឹងទេ? លក់ចាបហួយ និងធ្វើ
ស្លឹកណឹង ឬអ៊ីធ្លាប់ធ្វើអ្វីផ្សេងទៀត?
ខ៖ ឈប់អស់ហើយ ឈប់បានធ្វើអស់ហើយដែលលក់ចាប់ហួយអីក៏ឈប់អស់ដែរ
ព្រោះពីដើមមិញខ្ញុំលក់កន្លែងគេនៅពិការ
ខ្ញុំនៅផ្ទះជិតកន្លែងពិការកន្លែងមណ្ឌលគេ
ណា ទៅដល់នេះឡើងគេឈប់នៅទៅខ្ញុំក៏ឈប់លក់ ដល់ធ្វើស្លឹកទៅដាក់ម្ហ៊ីទៀត
ខ្ញុំឈប់ទៅបានម៉ាក់ខ្ញុំឈឺទៅក៏គាត់មកនេះមិនរួច ខ្ញុំមកជំនួសគាត់។
ក៖ ពីមុនម៉ាក់របស់អ៊ីគាត់មកនេះដែរមែន?
ខ៖ ចាសគាត់មកនេះ គាត់មានឈ្មោះនៅនេះនិងគេ តពីម៉ាក់មក។
ក៖ ចុះអ៊ីតើមានឧបសគ្គ ឬក៏ផលវិបាកអ្វីខ្លះក្នុងជីវិតនេះអ៊ី? អ៊ីរៀបរាប់ប្រាប់
បានទេអ៊ី?
ខ៖ និយាយទៅពិបាក ពិបាកមែនខ្ញុំ តាំងពីបានគ្នាមកខ្ញុំអាយុ២៧ថាឈឺ
ឈឺរហូតណា
ខ្ញុំឈឺ ប្តីខ្ញុំក៏ឈឺ កូនខ្ញុំក៏ឈឺ ណាមួយកូនប្រើនផង ថាខ្ទល់
ទៅក៏ខ្ញុំនិយាយទៅដល់រៀប
ចំតវ៉ាន់អីទៅក៏ត្រូថាឲ្យខ្ញុំមើលគេ ខ្ញុំមិនលាក់ទេខ្ញុំមើលគេ
បានខ្ញុំមើលទៅគេប្រាប់ថាកុំ
ឲ្យធ្វើស្រែ មិនធ្វើស្រែម៉េចបើកូនវាប្រើននោះបង
រត់តាមប្តីខ្ញុំទៅស្រែទៅធ្វើស្រែដាប់
ប៉ុន្ទានថ្ងៃក៏ មុនធ្វើស្រែនោះកាលមើលគេនោះគេទៅបោក
ខ្ញុំរកប្រាក់បានក៏គេបោក
អស់ទៅណា ដូចជាទិញរបស់មាសប្រាក់ពេជ្ជ អាណាគេបោកអស់១ដំឡឹង២ដី
កាលនោះមាសនៅផ្ទៃ ដល់ផុតពីបោកនោះទៅដើរតក់ៗបានទៀត
ដល់រកបានទៀត
ថាប្រុងធ្វើផ្ទះនៅលុស្ស្ជិតនិងគេហើយ ក៏ទៅស្រែជ្ជួតស្ទូរក្លឹងឆេះផ្ទះនេះអស់រលីង
ឆេះរម៉ក់ឆេះអីទៅណា មិនដែលមានសល់អីសូម្បីតែសម្លៀកបំពាក់ក៏មិនសល់
ទៅក៏

កូននៅតូចៗផងនៅរៀនក៏
ថាវាស្រែកយំថាវាឈប់រៀនហើយថាអាណិតកូនណាស់។
ក៖ ចុះអ៊ីបានផ្ទះណានៅពេលដែលឆេះផ្ទះណឹងហើយ?
ខ៖ ទៅក៏សល់រោងគោ ក៏ទៅនៅនិងរោងគោ បានអ្នកស្រុកដឹកខោអាវទៅឲ្យ
ដឹកអង្ក្រ
ទិញឲ្យ១បេទុកឲ្យ ថាគ្រឿងកែវអី ត្បាល់កិនអី
និយាយរួមទៅថាត្បាល់កិនអីវាចេះឆេះ
អស់ដែរ កំសៀវអីក៏ឆេះ មកពីឆេះខ្លាំងមែននោះឯងផ្ទះឈើ
មានឈើច្រើនក្នុងណឹងថា
ទុកធ្វើផ្ទះនោះ ទៅផ្ទះឈើហើយអារបស់អាចម៍ទៀនម៉ាក់ដែលគេអុជ
ម៉ាក់ខ្ញុំយកទៅ
ដាក់នៅនោះណាបង ២ការ៉ុង អាចម៍ទៀនណាបង ទៅដល់នេះឡើងវាឆេះឡើងងុំ
អត់ហ៊ុយណា បងអើយទៅសំណាក់ខ្ញុំនោះឯង
ឆេះអាកន្លែងនោះអស់ក៏ស្រាប់តែខ្ញុំ
ទៅច្រូតស្រូវជាមួយប្តីខ្ញុំនេះឯង ក៏ប្តីខ្ញុំគេបែរមើល
គេចាក់ទឹកឲ្យគេរួចណាគេចេញទៅ
ក៏ មើលមីនាង មើលមីនាង គេថាណា ខ្ញុំថាយីម៉េចក៏បន្ទាន់មាំម៉េស
មកគ្នាពរកូនហើយ
ក៏កូនច្រើនផងឆ្លងអូ ដើមឈើមួយបាក់កាត់អូរ ឆ្លងដើមឈើនោះណា
ទៅក៏ខ្ញុំនេះឯងក៏
គេច្រូតស្រូវគេ◌ែបរមើលមក គេលើកដៃជំពាក់ដៃគេជួយច្រូតគេ
ខ្ញុំក៏ទៅច្រូតស្រែខ្លួន
ឯង មើលកូនផង កូននៅតូច តាំងពី២០១៤ ភ្លើងឆេះផ្ទះនេះណា
ទៅក៏មិនសូវយូរណា
៦ឆ្នាំ ២០១៤គេទើបតែបង្កើត facebook នោះណា កាលនោះគេចាប់បង្កើតអា
facebook
២០១៤នោះឯង ខ្ញុំក៏ម៊ុងបាញ់មកនោះម៊ុងរឿនភ្លើងឆេះផ្ទះខ្ញុំហើយ
ម៉េចឯងដឹងម៊ុងរឿន
ថាចេះឯង ទៅក៏នេះឡើងគេថាខ្ញុំក៏រត់អត់រត់ទៅខ្ញុំទេ
ក៏រត់មកឯណោះឯងក៏យើញភ្លើង
ឆេះក៏អត់ចូលកើតព្រោះឆេះតាំងពីម៉ោង៦ កន្លះព្រឹក
ដល់ម៉ោង១១បានដឹងដែលសល់
បងផ្ទះឈើ រម៉ក់ធំ ម៉ូតូអីឆេះឡើងអស់
ទៅក៏ដល់នេះឡើងខ្ញុំក៏គេថាអ្នកស្រុកមើល
ជួយពន្លត់ដែរតែពន្លត់អត់បានទៀតវាឆេះពេញចំនួន
ទៅបានថាបើសិនជាមានអី
ផ្តាំគេផ្តាំឯងផ្តាំកូនចៅប្រដោយខោអាវកុំឲ្យតែដាក់មួយកន្លែងដូចខ្ញុំ
ពេលឆេះទៅគ្មានអី
ស្លៀកទេ បានតែមានរោងទៅពាក់នោះចោលខ្លះទៅ បងអើយគ្មានអីស្លៀក
សូម្បីតែ
កន្ទោបជូតក៏គ្មានអីសល់ និយាយពីខ្ញុំនិងបងម៉ែនរត់ទៅពីនេះឯងរត់ឆ្លងអូ
ចេះនាំកូន
ឆ្លងទឹកអូរនោះទៅ ទៅប្រាប់ខ្ញុំ ខ្ញុំមែនមិនមែន អត់ដឹងផងមែនមិនមែន
កាលនោះកុំអី
ខ្ញុំមិនទៅវង្វេងវង្វន់ចេញទេប៉ុន្តែខ្ញុំបាក់ទឹកចិត្តនិងម៉ាក់ខ្ញុំ
ព្រោះនៅជាមួយសុខៗហើយ
រត់ទៅនៅជាមួយសំ រត់ទៅនៅជាមួយកូនបង

ទៅក៏កូនខ្ញុំដាច់ដោះទៅទាវរកតែយាយ
ខ្ញុំអាណិតណាស់។
ក៖ អ៊ីផ្ទះឆេះណឹងមកពីវាក្តៅពេកឬក៏វាម៉េចដែរអ៊ុ?
ខ៖ ភ្លើងទានខ្ញុំអត់ពន្លត់ ដែលប្តីខ្ញុំហៅៗពេកក៏ទម្លាក់ទ្វារទៅខ្ញុំក៏ចុះទៅ
ក៏ទៅច្រូតនោះ
ណា គេមិនឲ្យខ្ញុំធ្វើស្រែនិយាយរួម ចុះទៅអត់បានពន្លត់វាក៏ភ្លើងឆេះ
បងខ្ញុំមីមួយស្រី
នោះវាមកទៅវាហៅរកខ្ញុំទៅមើលអី មើលអី ទៅក៏ឃើញភ្លើងឆេះហើយ
ថាខ្ញុំអុជទុក
តែចេះឯង ហើយអាចម៍ទៀនច្រើនថីវាមិនឆេះ
ទៅក៏ភ្លើងឆេះទៅដល់អាចម៍ទៀន
វាថា គេថាពន្លត់ឲ្យវាទៅវាមិនដែលអុជទុកចេះទេដែលគេមកជាមួយនោះណា
ទៅវា
ថាមិនអីទេមីនាងវាអុជទុកចេះឯងគេថាណា បើពន្លត់អត់អីទេ
ទៅក៏ខ្ញុំក៏នៅឯណោះ
ដល់ស្រាប់តែប្តីខ្ញុំនេះឯងរត់ទៅមីនាងអើយឆេះផ្ទះអស់ហើយថា
ខ្ញុំថាចុះរម៉េចម៉ែន
អស់រលីងហើយមានអ្នកពន្លត់ក៏ពន្លត់មិនកើត
វាចេះពេញចំនួនចូលម៉េចកើតថា
ទៅក៏ដើរខ្ញុំគ្រារដូលខ្ញុំគ្រាយកទៅដាក់និងខ្ទមវិញ
ខ្ទមឯងកន្លែងកូនដើរនោះឯងក៏
ដល់នេះឡើងក៏ មកមីនាងមិនបាច់ទៅមើលទេមីនាងទៅមើលក៏អត់
ខ្ញុំក៏មិនថាមិន
ដីងទេមីងអើយខ្ញុំវង្វេងចេះឯង ទៅក៏ជាប់អត្តសញ្ញាណបីណ្ឌនៅនិងខ្លួន
អត្តសញ្ញាណបីណ្ឌប្តីខ្ញុំហើយនិងរបស់ខ្ញុំ កុំអីអស់រលីង ទៅក៏ដល់នេះឡើងក៏
មកដល់ខ្ញុំរត់ទៅក៏ ដល់ម៉ោង១២បានខ្ញុំទៅសុះអស់នៅតែធ្យងទៅហើយ ដល់នៅ
តែធ្យងក៏គេទៅសម្ភាសន៍ គេទៅសម្ភាសន៍ដាក់វិទ្យនោះប្រធានភូមិគេសួរថា
ឆេះអស់
អ្វីខ្លះ ខ្ញុំអត់ដឹងទាំងអស់ ក៏អត់ដឹងអីទាំងអស់ក៏រឹងខ្លួនឆ្កឹត
រឹងខ្លួនឆ្កឹតក៏ពយប់ពាថ្ងៃក៏
នោះរឹងខ្លួនឆ្កឹតមិនដែលមានដឹងខ្លួនដឹងអី
វាដឹងតែដូចថាវាវង្វេងក្នុងសតិអស់ណា
មិនឃើញខ្ញុំថារកតែចាំអីកូនកើតមកខ្ញុំចាំខែថ្ងៃកូនអស់ណា
ដល់អាភ្លើងឆេះផ្ទះទៅមិន
ដែលរកខែថ្ងៃកូនឃើញ ទៅឆេះ ឆេះទាំងបញ្ជីរកំណើតអីអស់ណាមិនមានស្អីសល់
ទៅក៏ស្រាប់តែនេគេមកសួរទៅក៏អ្នកស្រុកក៏យកខោអាវហើយអង្ករ
តាំងពីគ្រែដេកភួយ
ម្ជុំង ឲ្យឡើងលើសចំនួន លើសចំនួនពីខ្លួនឯង
ពីរបស់ខ្លួនឯងលើសឡើងគេឲ្យច្រើន
តាំងពីខេត្តអីគេដឹក ដឹកឡានយកទៅឲ្យសុទ្ធតែខោអាវ ទៅខ្ញុំឲ្យគេវិញទាំងអស់
ចែក
ញាតិដែលក្រដូចគ្នាណា ដែលអត់ដូចគ្នាខ្ញុំទុកតែម៉ាស្លៀកបាន
បើអ្នកស្រុកក៏សារ៉ុង ប្រាក់ សារ៉ុង ប្រាក់ សារ៉ុង ប្រាក់ កាលណឹងគេជួយណា
ថាប្រាក់ប្រហែលជា៤០០នោះ
ឯង បើសារ៉ុង៣០ជាងហើយសារ៉ុងថ្មី
បើខោអាវដែលគេស្លៀកហើយនោះខ្ញុំអត់បាន
រៀបទេ វាច្រើន ភួយ ម្ជុំង កន្ទេលខ្ញុំចែកគេវិញ វាច្រើនណាទៅក៏ដល់នេះឡើងក៏

ខ្ញុំក៏ប្តីខ្ញុំដើរយល់សុបិន្តថានែមីនាងលោក ថាសុបិន្តឃើញពស់ថ្លាន់នោះថាឯង
ឈប់ពីបាកទៅ នែពស់ថ្លាន់មកប្រាប់ថានែ ថាឯងមកនេះបើភ្លើងឆេះផ្ទះមែន
ថាពស់
ថ្លាន់នោះហៅថាប្តីខ្ញុំណាទៅថារម៉េចទៅថា សួរថាមានអ្វីខ្លះ
ថាវិញខ្ញុំមិនដែលចាំបាន
ទេ ចាំបានតែអាគុយភ្លើងមួយ
អាគុយចាប់ភ្លើងកាលណឹងគេមិនទាន់តខ្សែភ្លើង ថា
មានតែអាគុយមួយ គេថាចុះម៉េចមានតែអាគុយមួយប៉ុណ្ណោះ
ប្តីខ្ញុំថាមានតែអាគុយ
មួយប៉ុណ្ណោះ ទៅក៏ស្រាប់តែនេះឯងក៏ យូរទៅៗបាន
ដូចជាគេធ្លាប់ទៅបានគេថាមាន
អានេះមានអានោះដែលឆេះ ឆេះអស់នោះណា
ទៅវាវង្វេងឯងខ្លួនស្រាប់តែស្អែកឡើង
លោកឯងទៅ យើញលោកថាញ្ញេមកុំអាលភ័យចាំអាស្នាធ្វើផ្ទះឲ្យ ទៅក៏លោកធ្វើឲ្យ
នេះណា បាននៅរាល់ថ្ងៃនេះ។
ក៖ ចឹងផ្ទះអ៊ុថ្មីណឹងលោកធ្វើឲ្យ?
ខ៖ ចាស លោកធ្វើឲ្យ លោកអង្គការជីវិត និង ក្តីសង្ឃឹម ឈ្នោះចុះឯង
ឈ្នោះចុះឯង
លោកនោះណា លោកបងជ្រឹមនៅវត្តគោកចកឈ្នោះគាត់ណា
លោកបងជ្រឹមនៅវត្ត
គោកចកដល់សព្វថ្ងៃគាត់ឡើងជាអធិការធំហើយ។
ក៖ អ៊ុបានផ្ទះណឹងឯងនៅដល់សព្វថ្ងៃនេះឯង?
ខ៖ ចាសនៅសព្វថ្ងៃនេះឯង ដំបូលស័ង្ករ ជញ្ជាំងស័ង្ករ
បើគ្រឿងឈើទាំងអស់ឯង
សរស ដាក់សរសជ្រុងឯង ជើងសរសគេដាក់មួយម៉ែត្រ អាជើងសរសស៊ីម៉ង
នោះណា។
ក៖ អ៊ុប្រហែលន្ទានឆ្នាំពេលអ៊ុឆេះផ្ទះណឹង បានគេធ្វើផ្ទះថ្មីឲ្យអ៊ុ?
ខ៖ ឆេះពីខែប៉ុន្ទានទេ ដូចខែ៧ ដល់ខែ១១គេធ្វើឲ្យ។
ក៖ ចឹងអ៊ុតើអ៊ុចាំរឿងអ្វីខ្លះកាលសម័យប៉ុលពត អ៊ុទាន់ទេអ៊ុ?
ខ៖ ខ្ញុំកើតអត់ទាន់ផង ខ្ញុំដឹងថាខ្ញុំកើតនៅតូចទៅ
ម៉ាក់ខ្ញុំ ុគេបើកអង្ករឲ្យមួយស្លាបព្រា
ថាទុកសន្សំឲ្យតែខ្ញុំ លឺម៉ាក់ខ្ញុំប្រាប់ចុះ បើរឿងទៀតអស់ស្គាល់ទេ។
ក៖ ប៉ុន្តែអ៊ុដូចចាំឪពុកម្តាយរបស់ដូចម៉េចអត់អ៊ុកាលជំនាន់ប៉ុល ពត
ថាគាត់វេទនា
ម៉េចខ្លះ?
ខ៖ វេទនាលឺគាត់ដឹងថាអត់ហូបប៉ុណ្ណោះណា បើរឿងអីទៀតខ្ញុំអត់ដឹងដែរ។
ក៖ តើអ៊ុឆ្លងកាត់ឧបសគ្គ និងផលវិបាកដែលអ៊ុនិយាយរឿងឆេះផ្ទះណឹង
អ៊ុឆ្លងកាត់
ដោយរបៀបណាអ៊ុ ដែលអ៊ុធ្វើចិត្តបានវិញចឹងណា?
ខ៖ ចាសដែលធ្វើចិត្តបាននេះនិងវិញ
លោកធ្វើផ្ទះឲ្យទៅក៏គាត់ពន្យល់ប្រាប់ថាកុំឲ្យ
គិតរឿងដើមថាឲ្យគិតរឿងជីវិតថ្មី ទៅខ្ញុំក៏ធ្វើតាមគិតតែជីវិតថ្មីទៅ
សុខៗក៏ជិះមកខ្ចី
ប្រាក់អង្ករ ភ្លើងឆេះផ្ទះរួចលោកធ្វើឲ្យនោះណា ដល់បានមួយឆ្នាំខ្ចីប្រាក់អង្ករ
ទិញម៉ូតូជិះ អាឆ្នាំ២០១៧នោះណា ទើបតែចេញជិះទៅទន្លេ
ជិះបាន៣ខែជិះទៅបង់
នៅទន្លេក៏ចោរលួចនៅនោះទៀត ស៊ីយឡើងបានលឺថារឿងខ្ញុំវាច្រើនណាស់ ក៏ខ្ញុំនិ

យាយម្សិលមិញខ្ញុំថាខ្ញុំបើកុំឲ្យតែហិនហោចច្រើនកុំអីខ្ញុំមិនដែលក្រចេះទេ
តែនេះឡើង
រកតែប្រាក់ដាក់បាតមិនមាន ឆ្កែឆ្គួតក៏ខាំប្ដីនោះទៀត។
ក៖ ចុះម៉េចបានឆ្កែខាំគាត់អ៊ុំ?
ខ៖ ឆ្កែឆ្គួតនោះណា កំពុងធ្វើការកន្លែងធ្វើការនាងឯងមើលវាចេះរត់
កំពង់ធ្វើការសុខៗ
ខាំប្ដីខ្ញុំ ខាំហើយក៏អត់ប្រាប់ភ្លាមៗ
បើថាឆ្កែឆ្គួតខាំឲ្យប្រាប់ភ្លាមឲ្យគេលាងម្សៅក្រូចអីឲ្យ
អូន ចេះខាពីថ្ងៃសុក្រដល់ថ្ងៃសៅរ៍បាននិយាយ ដល់និយាយទៅគេថាហី ទើបតែគេ
កន្លែងធ្វើការទេគេតែមក ហ្អែងបានចាក់នែ ចាក់វ៉ាក់សាំងហើយ
ខ្ញុំក៏សួរវ៉ាក់សាំងអី
ម៉ែន ឯងអើយគ្នាឆ្កែឆ្គួតខាំមិនហ៊ានប្រាប់ឯងរឿងច្រើនពេកថា តោះបងម៉ែន
ខ្ញុំរត់ទៅហៅពេទ្យរឿនហៅពេទ្យអ្នកស្រុកណា ដល់ពេទ្យមកដល់ថាពេទ្យអត់ហ៊ាន
ចាក់ទេ ព្រោះនែហ្អែងឆ្កែឆ្គួតខាំចេះ អញមិនដែលមានវ៉ាក់សាំងឆ្កែឆ្គួតខាំហា
ទៅក៏ហ្អែងទៅ១០២ទៅ ថាទៅ១០២នៅកន្លែងពេទ្យខេត្តយើង
មុនពេទ្យខេត្តគេហៅ
ពេទ្យ១០២ ទៅដល់គេចាក់ទៅគេថាចាក់ឲ្យវ៉ាក់សាំងតែការពារថ្ងៃនេះទេ
បើដល់ស្អែក
រយៈពេល១អាទិត្យ មនុស្សឆ្កួតចុះអង្រួងខាំទៅក៏រាងឡេឡឺណា
ទៅក៏បែកភ្នែកធំៗដាក់
ខ្ញុំណា ឡេឡឺចុះក៏ខ្ញុំថាចេញពីពេទ្យរឹងខ្ញុំស្រែកយំលើម៉ូតូឡើង អត់លុយនោះ ទៅក៏
គេឲ្យទៅពេទ្យកាលីម៉ែតនៅឯភ្នំពេញខ្ញុំអត់ស្គាល់
ទៅរកពេទ្យកាលីម៉ែត្ររម៉េចណាណី
ទេ ថាប្រវិត្តខ្ញុំមានរឿងច្រើនណាស់។
ក៖ ចឹងអ៊ុំនាំគាត់ទៅភ្នំពេញទៅ?
ខ៖ ចាសក៏ទៅភ្នំពេញដល់ថ្ងៃអាទិត្យនេះ គេឲ្យតែបានមួយអាទិត្យមនុស្សនេះឆ្កួត
ប្ដីខ្ញុំ
វាញ៉រញាក់ទៅហើយព្រោះអង្រួងខាំនោះ ចុះពីលើផ្ទះសុទ្ធតែអង្រួងដើមស្វាយច្រើន
ណា ទៅក៏បើម៉ែននៅផ្ទះទៅត្រួតចំការបានអង្រួងខាំខ្លាំងណាស់ណាបង
ទៅត្រួតចំការ
បានអង្រួងខាំច្រើនណាស់
បើនៅតែលើផ្ទះចុះពីលើផ្ទះគឺអង្រួងខាំបើយាយថាអង្រួងខាំ
មិនបាន
ចាសទៅក៏នេះឯងអ៊ុំមកនេះខ្ញុំប្រាប់ឱ្យបប្រាប់ខ្ញុំបងម៉ែនចេញមកក្រៅហើយ
ថាប្ដីអ៊ុំឯងបើមិនយកទៅចាក់វ៉ាក់សាំងនៅឯកាលីម៉ែត្រវ៉ាក់សាំងនៅពេទ្យកាលី
ម៉ែត្រទេ
ចាក់កាល់ស្យូមម៉េចនោះទេ   ចាក់ថ្នាំសារ៉ូមម៉េចទេគេថាការពារ
ទៅពេទ្យកាលីម៉ែត្រ
ទៅខ្ញុំសរសេរសំបុត្រឲ្យ ចុះមើលខ្ញុំអត់ស្គាល់បង្ហាញតែឡានក្រុងទៅដឹងហើយថា
ឲ្យឡានក្រុងក៏ទៅដែរដឹងគេឈប់តែកន្លែងផ្សារដើមគរនោះ
ដល់ផ្សារដើមគរខ្ញុំអត់
ស្គាល់ទៀត អូ!ថាប្រវិត្តវាល្អូកល្អឺនណាស់ គេឲ្យទៅចាក់ឡើង៥ដង
ចាក់ឡើងគ្រប់ទៅ
ហើយ ចាសការពារឲ្យតែ៦ខែទេក្នុងការចាក់បើសិនតែឆ្កែខំអីទៀត សារដើមវិញ
ក៏ទៅចាក់ទៅ បើក្នុងកំឡុងពេលចាក់ណឹងគេសន្យាថា៦ខែទេ
វាដាច់ចាក់នោះណា
វាឈប់ការពារបានថ្នាំនោះណា អត់មានការពារមួយជីវិតទេ។

ក៏ តែគាត់ឥឡូវអត់អីណាអ៊ីហ?
ខ៏ ឥឡូវអត់អីទេ ទៅក៏ដល់នេះឡើងខ្ញុំ
មានស្ទីគាក់ តិចក៏លក់អស់យកទៅមើលទៅ
ទៅភ្នំពេញទៅយប់ផងថ្ងៃផង ដេកជិះឡានឈប់ក៏ទៅ ទៅចាក់ទម្រាំអាដាច់នោះ ដល់
អាធ្វើស្លេរបានដាក់ចំបើងកៀនខ្ទមនោះ ភ្លើងវាឆេះឡើងលេចខ្ទម
ពិបាកប្រធានភូមិ
មកហៅម្ចាស់ដល់ផ្ទះទៀត ថាមីងកម្ពណាស់ ខ្ញុំមានប្រវ៉ិត្តច្រើនឡើង អត់បានចងគោផង យកគោចេញចងក្រៅ បើចងក្នុងដាប់អស់ដំបូងស៊ីស្ពីស
ស្រាប់តែឃើញ
ហាមខ្លួនខ្ទៅរត់មក ថាមីនាងអើយកុំឲ្យបន្ទោសគ្នា
នែថាភ្លើងវាឆេះចំបើងអស់ទៅ
ហើយបើកុំឲ្យតែ ក្ងាដែលដឹងឯងអើយ ក្ងាដុតអង្ការមពីល្ងាចថា
ដុតអង្ការមពីល្ងាចបើ
កុំឲ្យថានែ ទៅមើលពីថ្ងៃអត់មានអីទេ
ស្រាប់តែមកដល់ផ្ទះក៏ឃើញប្រធានភូមិមក
ម៉ារិននោះប្រធានភូមិ រត់មកប្រាប់ថាភ្លើងឆេះលិចដំបូលហ្អែង
កុំឲ្យតែស៊ីស្ពីសកុំអីឆេះ
អស់ហើយ ហ្អែងបើចងគោនៅកៀនចំបើងនោះអី គោ២ ៣ទាំងកូន
កុំអីវេទនាកម្ម
ពារនោះទៀត អូថាប្រវ៉ិត្តរបស់ខ្ញុំច្រើនណាស់ ទើបស្ងាត់ប្រហែលមួយឆ្នាំនេះឯង
ថាមួយឆ្នាំហើយក៏ម៉ាក់ខ្ញុចទៀត ម៉ាក់ខ្ញុច បងក៏ដាប់ ម៉ាក់ក៏ខ្ញុចទៅ
បើបងដាប់មិនដែល
ពិបាកលុយខ្ញុំ បើម៉ាក់ខ្ញុំនេះណាពិបាកនិងខ្ញុំ
ព្រោះគាត់អត់មានលុយទុកលុយដាក់
បើគាត់រកបានអាល័យតែសប្ដាយនោះកាលណោះ ថាខ្ញុំវា ថាទុក្ខរហូត តែកូនក៏
ត្រូវ
ធម៏ដែរវាចេះតែមើលមុខ មើលមុខទៅវាធ្វើតាមដែរ បង្ហាប់វាទៅក៏
ធ្វើបុណ្យម៉ាក់
ម៉ែជំពាក់គេ១០០០ ថាកូនអើយកូនឯងរកដោះទៅ កូនឯងធ្វើការបានមួយខែ
១០០ ក៏ដោះ ដោះ ដោះគេនោះឯង មិនដែលបានទុកដាក់ទេឲ្យទាំងអស់១០០
១០០
ដល់ទៅជំពាក់អង្ការនោះ ប្ដីខ្ញុំបើកមកក៏ដោះៗអង្ការនោះឯងបានថា
ខ្ញុំមកនេះបាន
ត្រាក់ៗ តាំងពីភ្លើងឆេះផ្ទះនោះឯងលោកមើលឲ្យនែថា ពីដើមឡើយមិនដែលបាន
ស្គាល់ជាតិការងារអីធ្វើទេ សុំទៅណាក៏មិនដែលបានដែរ ដល់ភ្លើ◌ងឆេះផ្ទះទៅនេះ
លោកឲ្យមកអង្គុយមើលដីឲ្យទៅ
នែឲ្យនៅត្រង់នេះទៅថាលោកធ្វើផ្ទះឲ្យទៅក៏ឲ្យមើល
ដីឲ្យស្ងួតណា
ទៅក៏លោកថាញ្ញោមឯងថាបានគេធ្វើផ្ទះឲ្យក៏បានការងារធ្វើថាណា
ដល់គេធ្វើផ្ទះឲ្យ លោកធ្វើផ្ទះឲ្យក៏ទៅសុំការងារគេធ្វើក៏បានធ្វើណា ធ្វើចុះធ្វើឡើង
ខ្ញុ្ជំទារនោះគេនាំទៅធ្វើនោះ តែថាមិនដែលចេះអក្សរដែលមិនបានលុយផ្ដែ
១ខែ
២០០ប៉ុណ្ណោះ ដល់សេដ្ឋកិច្ចគេធ្លាក់ចុះចេះ គេកាត់ចោល២០ដុល្លារ គេឲ្យតែ១៨០
ទៅក៏បងដ៏អង្ការ១៨០នោះ ប្រាក់ខែទាំងអស់ណឹង។
ក៏ តែឥឡូវគាត់នៅតែធ្វើការទេអ៊ីរ?
ខ៏ នៅ នៅធ្វើការ?
ក៏ គាត់ធ្វើអីគេអ៊ីរ?

ខ៖ ប្តីខ្ញុំមើលភ្លើងផង មើលផងចុះយើងអត់ចេះ កុំអីឲ្យមើលកាលីនោះឯង។
ក៖ តាត់ធ្វើយូរហើយអ៊ុំ?
ខ៖ ចាស តាំងពីភ្លើងឆេះផ្ទះនោះឯង ៦ឆ្នាំហើយ
កាលភ្លើងឆេះផ្ទះនោះសល់គោ១នឹម
ផុតពីនោះមិនមានសល់អី អស់រលីងសល់តែគោ១នឹម។
ក៖ អ៊ុំ ចឹងតាំងពីក្មេងរបស់មកដល់ពេលនេះ តើជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរ
អីអត់អ៊ុំ? ដូចពីមុនធ្លាប់ពិបាកដល់ឥឡូវរាងស្រួលជាងមុនឬក៏ម៉េចដែរអ៊ុំ?
ខ៖ ដល់សព្វថ្ងៃអស់កូនអស់ចៅទៅវាស្រួលហើយ អត់ពិបាកដូចមុន
ចាសពិបាកនិង
កូន៣ឆ្នូ ៣ ២ ៣ ២ ហើយទៅរកស៊ីអីបាននាង កូន៣ឆ្នាំ២
តែនិយាយរួមទៅកាលនោះ
ដូចរកស៊ីធូរដែរ លក់ឥវ៉ាន់ទៅក៏យើងនៅផ្ទះបាន ចាសកូន៣ឆ្នាំ ២។
ក៖ ចឹងអ៊ុំ អ៊ុំចងចាំពីពេលវេលដែលអ៊ុំសប្បាយចិត្តជាងគេក្នុងជីវិតទេ
អ៊ុំចាំទេថាពេលណា?
ខ៖ សប្បាយ សប្បាយៗកាល កាលកូននៅតូចៗនោះសប្បាយដែរ
ដល់ខ្ញុំអស់កូនទៅ
ដូចជាវាហិនបំផ្លាញទៅមិនដឹងរម៉េចចុះ
សប្បាយតែកូននៅតូចៗដល់កូនធំទៅអត់
សប្បាយទេ អត់សប្បាយអាល័យរកអីឲ្យកូនរៀនមែនណាបង អត់សប្បាយទេ
កើត
ទុក្ខ។
ក៖ អ៊ុំ កាលអ៊ុំនៅពីក្មេងអ៊ុំមានក្តីស្រម៉ៃចង់ធ្វើអ្វីដែរពេលអ៊ុំធំឡើង?
ខ៖ ធំឡើងនោះមិនដែលមានចង់ធ្វើអី ចង់តែនៅផ្ទះមើលថែកូន
តាំងពីតូចមកស្រម៉ៃ
ចង់រកតែសុំប្តីកុំឲ្យចេះផឹកចេះលេង
ហើយក៏ចេះស្តាល់រកប្រាក់បានក៏ចេះឲ្យខ្ញុំកាន់ ទៅ
ក៏បានដូចចិត្តចឹង។
ក៖ ចឹងបានន័យថាក្តីស្រម៉ៃរបស់អ៊ុំក្លាយជាការពិត?
ខ៖ នោះឯង អាខ្លះគេស្រម៉ៃចង់ទៅកើតអ្នកចម្រៀងគេធ្វើបុណ្យអី
ខ្ញុំមិនដែលចង់កើត
ទេ ខ្ញុំចង់តែកើតមនុស្សល្អ ចិត្តល្អចេះធ្វើបុណ្យធ្វើទានហើយក៏ចង់បានកូន
ឲ្យកើតកូន
ស្រីទៀតទៅចុះ ខ្ញុំមិនដែលចង់កើតកូនប្រុសទេ សុំបានតែកូនស្គាល់ម៉ែស្គាល់ឪ
ចង់ឲ្យ
កូនបានប្តីទៅបានតែសុខគ្រប់ៗគ្នាដូចតែខ្ញុំនិងឪវាមិនដែលចេះឈ្លោះគ្នា
មិនដែលនិ
យាយអាក្រក់ ឬ បន្ទោសខ្ញុំមួយម៉ាត់ទេ មិនដែលនិយាយពាក្យអាក្រក់ទេ
សុទ្ធតែគ្នា
ឯង និយាយទៅមិនដែលឈ្លោះគ្នាតាំងពីបានគ្នាមកណា
ចាសខ្ញុំសូមបន់ប្រថ្នាអីឲ្យតែ
កូនខ្ញុំជួបដូចរូបខ្ញុំទៅមុខចាស។
ក៖ អ៊ុំតើម្ហូបណាដែលអ៊ុំចូលចិត្តពិសារជាងគេដែរ?
ខ៖ ម្ហូបដូចខ្ញុំនិយាយចឹងមានតែសម្លរប្រហើរ សម្លរការកូ ម្ហូរក៏អស់សូវចូលចិត្ត
ប្រហើរ
ការកូអីចូលចិត្ត។
ក៖ តើអ៊ុំចូលចិត្តស្តាប់ចម្រៀងអីអត់អ៊ុំ
មានបទចម្រៀងណាដែលអ៊ុំចាំស្រលាញ់ជាងគេ?

ខ៖ មិនដឹងចូលចិត្តបទចម្រៀងអី ស្តាប់តែសារិន្ធអីប៉ុណ្ណោះ
ចង់ស្តាប់ចង់សើចមើលក្តង
ទូរស័ព្ទក្តន។
ក៖ ចុះអ៊ុចេះលេងឧបករណ៍តន្ត្រីទេអីអត់អ៊ុ?
ខ៖ មិនដែលចេះទេ ពីដើមមិញចេញលេងឃើមតិចដែរប៉ុន្តែភ្លេច កាលពីនៅក្រមុំ
បងខ្ញុំដែលអាប្រុសនោះចេះវ៉ៃភ្លេង ចេះលេងភ្លេងទៅបង្ហាប់ខ្ញុំចេះវ៉ៃឃើមដែរ
ទៅក៏ដល់
ឡើងក៏ភ្លេចអស់ទៅណា។
ក៖ ចុះនៅក្រុមក្នុងគ្រួសារអ៊ុមាននរណាចេះលេងឧបរកណ៍តន្ត្រីអីអត់?
ខ៖ អត់ទេនាងអត់មាននរណាចេះទេ។
ក៖ តើអ៊ុចូលចិត្តលេងល្បែងប្រជាប្រិយខ្មែរទេអ៊ុ កាលអ៊ុនៅក្មេង នៅក្រមុំអីណា?
ខ៖ មិនដែលបានលេងអីទេ។
ក៖ អ៊ុ ឥឡូវជាចុងក្រោយ តើអ៊ុមានអ្វីចង់ផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយ
របស់អ៊ុទេ? ថាពួកគេត្រូវរស់នៅធ្វើជាមនុស្សប្រៃបណាក្នុងសង្គមចឹងណា?
ខ៖ កូនចៅទាំងអស់គ្នាដូចកូនខ្ញុំដូចកូនគេណឹងហើ ខ្ញុំចង់កុំឲ្យជក់គ្រឿងញៀន
ឲ្យជៀសវាង ហើយឲ្យបើកម៉ូតូអីឲ្យប្រយ័ត្នផង កុំឲ្យគ្រោះថ្នាក់ចរាចរណ៍ ឲ្យគោពរ
ច្បាប់ចរាចរណ៍ ហើយឲ្យបើកម៉ូតូតិចៗ បន្ថែមល្បឿន បើកតិចៗបើកុងទ័រ៤០អី
បើក២០អីទៅណា ខ្ញុំផ្តាំផ្ញើរទៅឯណោះចុះឯង ទាំងកូនខ្ញុំកូនគេ សូមឲ្យសុខ ឲ្យខំ
រៀនសូត្រឲ្យចេះដឹងជួសង្គមទៅមុន ថាឈានទៅមុខឲ្យបានល្អនិងគេ
សង្គមរម៉េច
គេជឿនលឿនទៅចុះ ហើយសូមឲ្យសុខសប្បាយទាំងអស់គ្នាចុះឯង ជូនពរនាង។
ក៖ ចឹងអរគុណច្រើនអ៊ុ ដែលចំណាយពេលឲ្យខ្ញុំសម្ភាន់អ៊ុហើយខ្ញុំសូមជូនពរឲ្យ
អ៊ុដូចគ្នាឲ្យមានសុខភាពល្អ និង មានសុភមង្គលក្នុងក្រុមគ្រួសារ ហើយសូមឲ្យអ៊ុ
ជួបប្រទះតែក្តីសុខ កុំឲ្យជួបបញ្ហារដូចអ៊ុរៀបរាប់ខាងលើ
ឲ្យតែអ៊ុជួបក្តីសុខទៅមុខ
ទៀតចឹងណាអ៊ុ។
ខ៖ សាធុ! សាធុ!
ក៖ ចាសអរគុណច្រើនអ៊ុ។